អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ល្បែង៖ ផ្តុំកូនបាល់

**កម្មវិធីសិក្សា៖**

**ចិត្តចលភាព៖** បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**សិក្សាសង្គម៖** គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព៖

**រយៈពេល៖** ៣០ នាទី

**ឧបករណ៍៖** ក្រដាសកេះ កាវ កន្ត្រៃ ក្រដាសជូតមាត់ប្រភេទណាក៏បានដែរ ទុយោរមួយចំនួន។

**គោលបំណង៖**

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។ បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(សិក្សាសង្គម)** ប្រាប់បានពីការបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… និងបង្កើតរូបភាពផ្សេងៗ។

**ត្រៀម៖**ធ្វើសម្ភារ១ឬ២ឈុតសម្រាប់បង្ហាញកុមារមុនពេលដែលត្រូវលេងល្បែងសកម្មភាពមួយនេះ។

**សេចក្តីណែនាំ៖**

១. ប្រាប់កុមារថា ថ្ងៃនេះពួកយើងនឹងលេងល្បែងសកម្មភាពមួយដែលឈ្មោះថា ល្បែងផ្តុំកូនបាល់។

២. សួរក្មេងៗថា ធ្លាប់លេងបាល់ដែរឬទេ? លេងនៅណា? លេងជាមួយអ្នកណា?

៣. ត្រៀមសម្ភារដែលត្រូវលេងក្នុងល្បែងសកម្មភាពមួយនេះឱ្យបានរួចរាល់ ១ ឬ២ឈុត ទៅតាមចំនួនកុមារដែលមានក្នុងថ្នាក់របស់អ្នក។

បង្រៀនកុមារឱ្យចេះធ្វើសម្ភារសម្រាប់លេងល្បែងនេះជាមុនសិន ដូចគ្នា ធ្វើបង្គោលទី និងកូនបាល់…

- កាត់ក្រដាសកេះធ្វើជារាងបង្គោលទី ទៅតាមចំនួនកុមារ
- ប្រើក្រដាសកាសែត ក្រដាសអនាម័យ ឬក្រដាសធម្មតា លុញវាជាកូនបាល់តូចល្មមដែលស្រាលនិងងាយស្រួលក្នុងការផ្តុំផងដែរ។

- ប្រើទុយោរក្នុងការផ្តុំកូនបាល់នោះ។

៤. ល្បែងនេះអាចលេងជាក្រុមក៏បាន លេងម្នាក់ៗក៏បានដែរ។

៥. គ្រាន់តែឱ្យកុមារលេងផ្តុំកូនបាល់ក្រដាសឱ្យចូលក្នុងទីម្នាក់ម្តងៗ គឺជាការស្រេច។

៦. ប្រសិនបើលេងជាក្រុមគឺៈ

- ចែកក្មេងៗទៅជាក្រុមដែលមានចំនួន២នាក់ ដែលជាគូរ ដើម្បីធ្វើការប្រណាំងគ្នាក្នុងកាលេងល្បែងនេះ។
- ក្មេងពីរនាក់ដែលជាគូរនឹងគ្នា ត្រូវប្រណាំងគ្នា ផ្តុំបាល់ឱ្យចូលទី។
- ទីលាន យើងអាចប្រើតុសម្រាប់ធ្វើជាទីលានបាន។ ដាក់តុពីរតំរៀបគ្នា។
- ក្មេងណាដែលផ្តុំចូលមុនត្រូវក្លាយជាអ្នកឈ្នះ និងត្រូវឈរនៅកន្លែងអ្នកឈ្នះសិន និងអ្នកចាញ់ឈរតាមអ្នកចាញ់ដែរ។
- ប្រណាំងមួយគូហើយ មួយគូទៀត រកអ្នកឈ្នះ
- ចាប់ផ្តើមឱ្យអ្នកឈ្នះប្រណាំងផ្តុំជាបន្តមួយអ្នកឈ្នះវិញម្តង ដើម្បីរកអ្នកឈ្នះទី១ ទី២ ទី៣ រហូតចឹងទៅ។
- អ្នកដែលចាញ់គ្មានសិទ្ធិប្រកួតទៀតទេ ទាល់តែអស់មនុស្ស និងចាប់ផ្តើមលេងល្បែងនេះម្តងទៀត។
- ប្រសិនបើមានពេលច្រើនអាចលេងម្តងទៀត ឬឈប់លេងប្រសិនបើអស់ពេលផងដែរ។

៧. ប្រសិនអាច អ្នកអាចបង្រៀនកុមារឱ្យចេះធ្វើសម្ភារសម្រាប់លេងល្បែងនេះបានកាន់តែល្អ ព្រោះពួកគេអាចធ្វើវាលេងនៅតាមផ្ទះរៀងៗខ្លួនបានទៀត។

៨. ពេលដែលលេងរួចរាល់ ប្រាប់ឱ្យកុមារជួយក្នុងការរៀបចំកន្លែង និងសម្ភារឱ្យបានរៀបរយ និងស្អាតជាការស្រេច។